គណៈកម្មាធិការព្រំដែនកម្ពុជា
សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ
Comité des Frontières du Cambodge ( C F C )
Cambodia's Border Committee ( C B C )
ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

*រំលឹកខួបទី១ នៃ "សន្ធិសញ្ញាបំពេញបន្ថែម" ចុះថ្ងៃទី១០ តុលា ២០០៥*

# "ការសម្ងាត់" នៃសន្ធិសញ្ញា ឆ្នាំ១៩៨៥ កំណត់ព្រំដែនថ្មី រវាងកម្ពុជា–វៀតណាម

## "ការសម្ងាត់"

មួយឆ្នាំមុននេះ នាថ្ងៃទី១០ តុលា ២០០៥ លោក ហ៊ុន សែន បានចុះហត្ថលេខា ជាមួយក្រុងហាណូយ នូវ"សន្ធិសញ្ញាបំពេញបន្ថែម" លើសន្ធិសញ្ញាមួយរបស់វៀតណាម នៃឆ្នាំ១៩៨៥ ដើម្បីកំណត់ជាថ្មី នូវគំនូសព្រំដែន រវាងវៀតណាមនិងកម្ពុជា ។ ការបោះបង្គោលទី១នៃព្រំដែនថ្មីនេះ បានធ្វើឡើងនាថ្ងៃទី៧ កញ្ញា ២០០៦ នៅភូមិបាវិត ក្នុងខេត្តស្វាយរៀង ។

សារព័ត៌មាន "កមបូត្យ ស្វ័រ" (Cambodge Soir)(១) ដែលបានទៅពិនិត្យពិធីនោះ បានសរសេរថា៖ "... ពួកអាជ្ញាធរ(ទាំងពីរប្រទេស)បានបោះបង្គោលសេមាថ្មី នៅត្រង់កន្លែងបង្គោលមួយ ដែលគេបានបោះកាលពីឆ្នាំ ១៩៨៦ គឺបង្គោលដែលសហគមន៍អន្តរជាតិ មិនបានទទួលស្គាល់សោះឡើយ ដោយបុព្វហេតុថា នាពេលនោះ វាមានកងទ័ពវៀតណាម លើទឹកដីកម្ពុជា ។" ការបញ្ជាក់របស់សារព័ត៌មាននេះ វាដូចជាការរំលឹកអំពីបញ្ហាមនសិការ របស់ពួកអ្នកដឹកនាំខ្មែរ"ជាន់ខ្ពស់" ដែលបានចុះហត្ថលេខា បានអនុម័ត បានផ្តល់សច្ចាប័ន និងបានផ្សាយឲ្យអនុវត្ត នូវ"សន្ធិសញ្ញាបំពេញបន្ថែម"នោះ ។ សារព័ត៌មានបានកត់ចំណាំបន្ថែមថាប្រជាពលរដ្ឋខ្មែរមិនត្រូវបានពួកអាជ្ញាធរហៅរក ឲ្យចូលរួមពិធីបោះបង្គោល ដែលគេប្រកាសថាវា"ជាប្រវត្តិសាស្ត្រ"នោះទេ ព្រោះពិតជាដោយសារ គេខ្លាចក្រែងប្រជាពលរដ្ឋខ្មែរ ទៅរំលឹកគេថាកន្លែងបង្គោលថ្មីនោះក្តី កន្លែងប៉ុស្តិ៍ព្រំដែនថ្មីវៀតណាមក្តី និងទីដីនៅឯនាយខ្លះទៀតនោះក្តី គឺសុទ្ធជាដីខ្មែរទាំងអស់ "នៅមុនពួកខ្មែរក្រហម"មកដល់ នាឆ្នាំ១៩៧៥ ។

"សន្ធិសញ្ញាបំពេញបន្ថែម" លើសន្ធិសញ្ញាទឹកដី នៃឆ្នាំ១៩៨៥ នេះ វាមានប្រវត្តិវែងឆ្ងាយ ដោយបត់បែនច្រើនណាស់ ព្រោះវាជាប់និងប្រវត្តិ នៃ"ដំណើរទៅទិសខាងត្បូង"របស់យួន ។

ការគំរាមជាប្រពៃណីរបស់វៀតណាម មកលើបូរណភាពទឹកដីកម្ពុជា បានកើតឡើងជាថ្មី ជាមួយនិងកំណើតនៃកងកម្លាំងវៀតមិញ ចាប់ពីដើមសង្គ្រាមលោកលើកទី២ នៅពេលដែលបារាំងចុះថយអានុភាព នៅឥណ្ឌូចិន និងក្រោយពេលដែលកម្ពុជាបានឯករាជ្យ នាឆ្នាំ១៩៥៣ ។ ពួកវៀតណាម ទាំងខាងជើងទាំងខាងត្បូង ដែលមានកម្លាំងសឹកខ្លាំងក្លា តែងបំពានលើខ្សែបន្ទាត់ព្រំដែនតាមច្បាប់អន្តរជាតិ រវាងវៀតណាមនិងកម្ពុជាឥតស្រាកស្រាន្ត ទោះបីគេបានបារាំង កាត់ដីកម្ពុជាក្រោមទាំងមូល ទៅឲ្យគេ ដោយអយុត្តិ-

C/O M. SEAN - 8, Ave du Golf 77600 Bussy St Georges France - http://www.cfcambodge.org
Téléphone : +33(0)607 955 366 - Fax : +33(0)160 951 281 - Email : secretariat@cfcambodge.org

ធម៌និងសោកនាដកម្ម ដល់កម្ពុជា និងប្រជាជនខ្មែរ ជាខ្លាំងហើយក្តី ។ ព្រោះតែការគំរាមរបស់វៀតណាម នេះ ទោះបីសន្ធិសិទ្ធអន្តរជាតិ នៅក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ បានទទួលស្គាល់ជាឧឡារិក នូវបូរណភាពទឹកដី កម្ពុជាហើយក្តី ក៏នយោបាយទូត របស់ព្រះករុណា នរោត្តម សីហនុ នាសម័យ“សង្គមរាស្ត្រនិយម” មានតែ ការទាមទារជានិរន្តរ៍ ដល់រដ្ឋបរទេសនានា ជាអាទិ៍គឺវៀតណាម (ខាងជើង និងខាងត្បូង) និងថៃឡង់ ឲ្យទទួល ស្គាល់បូរណភាពទឹកដី កម្ពុជា ។ ជាបន្ទាប់ របបសាធារណរដ្ឋខ្មែរ នៃលោកឧត្តមសេនីយ លន់ នល់ បាន លើកច្បាស់ នាខែមេសា ១៩៧០ ថាកងទ័ពកុម្មុយនិស្ត៍យួន បានចូលលុកលុយ និងកាន់កាប់ខេត្តខ្មែរធំៗ នៃ ទីសល្វសាន - ហើយវាធ្វើជាទីតាំងមូលដ្ឋានសឹក បញ្ជូនកងទ័ពឲ្យវាយប្រហារ អន្តរាយដល់បេះដូងនៃកម្ពុជា តែម្តង ។ លុះដល់សម័យកម្ពុជាប្រជាធិបតេយ្យ ពួកអតិត“បងប្អូនរួមអាវុធ” យួនក្រហម និងខ្មែរក្រហម ក៏ កើតជម្លោះ តាំងពី ឧសភា ១៩៧៥ ឥតប្រកបេញ រហូតដល់ច្បាំងស៊ីសាច់ហុតឈាមគ្នា នៅតែលើរឿងយួន រំលោភព្រំដែនដដែលនេះដែរ ។

នៅទីបញ្ចប់ កងទ័ពកុម្មុយនិស្ត៍វៀតណាម បានវាយយកបាន និងកាន់កាប់កម្ពុជា នាឆ្នាំ១៩៧៩ ហើយ បាត់តាំងរបបខ្មែរជារណបមួយ ហៅថា “សាធារណរដ្ឋប្រជាមានិតកម្ពុជា” (ស.ប.ក.) តំណាងដោយបក្ស មួយ ដែលគេផ្សំធាតុគ្រប់បែបឲ្យ និងមានឈ្មោះថា“បក្ស ប្រជាជនបដិវត្ត កម្ពុជា” (សព្វថ្ងៃហៅថា “បក្ស ប្រជាជនកម្ពុជា”) សំរាប់ឲ្យស៊ីញ៉េភ្លាមៗ នូវសន្ធិសញ្ញានិងកិច្ចព្រមព្រៀងកាត់ដែនសមុទ្រ (នាឆ្នាំ១៩៨២) និងកាត់ដែនដីគោក (នាឆ្នាំ១៩៨៥) របស់កម្ពុជា ឲ្យទៅវៀតណាម ។ យើងសូមបញ្ជាក់ថា ក្រោយពីការចុះ ហត្ថលេខា នាឆ្នាំ១៩៨២កាត់កោះត្រល់ (យួនហៅថា “ភូកុក”) និងបែកដែនសមុទ្រ “ទឹកប្រវត្តិសាស្ត្រ” ឲ្យ ទៅវៀតណាមហើយ គេបានចរចាគ្នាកំណត់ព្រំដែនជាថ្មី លើដីគោកទៀត ប្រវែង១២៧០គ.ម. តាំងពីឆ្នាំ ១៩៨៣ ១៩៨៤ រហូតដល់ការចុះសន្ធិសញ្ញា នាឆ្នាំ១៩៨៥ ។ នៅក្នុងសន្ធិសញ្ញា នៃឆ្នាំ១៩៨៥នេះ គេបានឲ្យ ពួកខ្មែរ សន្យាជាមុន ថានឹងគោរពចំពោះបង្គោលសេមា ដែលគេនឹងបោះពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៨៨ ។

ប៉ុន្តែ នៅចំពោះមុខ នៃការចុះសន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងអស់នេះ ពួកខ្មែរខាង“បក្សប្រជា-ជនបដិវត្តកម្ពុជា” ក៏មិនចុះសំរុងទាំងអស់គ្នាដែរទេ ។ លោកប៉ែន សុវណ្ណ ត្រូវកងកម្លាំងវៀតណាម អម ដោយលោក ហ៊ុន សែន និង សាយ ភូថង ចាប់យកទៅដាក់គុក (នាខែធ្នូ ១៩៨១) ។ លោក ហេង សំរិន - យោងតាមឯកសារ របស់អ្នកស្រាវជ្រាវអាមេរិកាំង ឈ្មោះ អ៊ីវ៉ាន ហ្គូតេសម៉ាន (Evan Gottesman) (២) - លោក ហេង សំរិន ជាប្រធាននៃក្រុមប្រឹក្សារដ្ឋ (ប្រមុខរដ្ឋ) ដែលធ្លាប់បានប្រឆាំង និងការចូលធ្វើនិគមន៍ យ៉ាងសន្ធឹកសន្ធាប់ នៃជនជាតិវៀតណាម“ថ្មីៗ” ក្នុងកម្ពុជា (៣) ក៏បានជំទាស់និងការបោះបង្គោលព្រំដែនថ្មី នៅពេលនោះដែរ ដោយពន្យល់ទៅលោក ហ៊ុន សែន ថា“វាគ្មានការចាំបាច់ នឹងផ្លាស់ប្តូរបង្គោល ដែលខ្មែរ និងវៀតណាមបានបោះជាមួយគ្នារួចហើយ ក្នុងកាលសម័យបារាំង នោះទេ” ។ ចំណែកឯលោក ចាន់ វ៉ែន ដែលជាអគ្គលេខាធិការ នៃក្រុមប្រឹក្សារដ្ឋ ក៏បានប្រឆាំងនិងការកាត់ដីខ្មែរ នៃខេត្តស្វាយរៀង ឲ្យទៅ វៀតណាម ហើយលោកបានធ្វើសេចក្តីរាយការណ៍ ឲ្យដល់សមាជិកនៃសភារបស់ស.ប.ក. ថែមទៀត។

រឿងដោយឡែក គឺពេលនោះ គេបានបង្កើត“គណៈកម្មការចំរុះ វៀតណាម-ខ្មែរ”មួយ ដើម្បីធ្វើ “ការចរចា”គ្នា អំពីបញ្ហាព្រំដែន ។ ខាងភាគីខ្មែរ មានជាអាទិ លោក ឱត មុន្នី និង ហោ ណាំហុង បន្ទាប់មកគឺ លោក គង់ គាំ ដែលជំនួស ឱត មុន្នី ដោយអ្នកទាំងនេះត្រូវនៅក្រោម “ការដឹកនាំ យ៉ាងល្អិតល្អន់”ជានិច្ច នៃ លោក ហ៊ុន សែន ជារដ្ឋមន្ត្រីការបរទេស និង“អ្នកជំនាញការ”វៀតណាម នៅក្រសួងការបរទេសនោះ ។ ជា ច្រើនឆ្នាំបន្ទាប់មក ក្នុងរឿងកិច្ចព្រមព្រៀងឆ្នាំ១៩៨២ កាត់កោះត្រល់ និងបែកដែនសមុទ្រ“ទឹកប្រវត្តិ-សាស្ត្រ”ឲ្យយួន លោក ហោ ណាំហុង(ជារដ្ឋមន្ត្រីការបរទេស) បាន“ផ្អូញ”ប្រាប់អ្នកស្រាវជ្រាវអាមេរិកាំង ថា“ខ្សែបន្ទាត់ប្រេវីយេ (Brévié) នោះ មិនមែនជាខ្សែបន្ទាត់ (ព្រំដែនសមុទ្រ)ទេ ។ ការពិត ទឹកន្លែងនោះ (កោះត្រល់ និងដែន“ទឹកប្រវត្តិសាស្ត្រ”) ជារបស់យើង(ខ្មែរ) តាំងពីសម័យបារាំង មកទល់ពេលនេះ” ។ ប៉ុន្តែ ទោះបីមានការជំទាស់ពីខាងខ្មែរ យ៉ាងណាក្តី - តាមការបញ្ជាក់របស់លោកអ៊ីវ៉ាន ហ្គូតេសម៉ាន - ក៏ “លោក ហ៊ុន សែន នៅតែជំរុញការចុះសន្ធិសញ្ញាទាំងនោះ ទៅមុខជានិច្ច ដើម្បីបង្ហាញឲ្យវៀតណាមឃើញ ថាគាត់ប្តេជ្ញាជាដាច់ខាត ទទួលការខុសត្រូវម្នាក់ឯង (ទល់និងអ្នកឯទៀតទាំងអស់)” ។ ដោយឡែកទៀត ទោះ នៅក្នុង“គណៈកម្មការចំរុះ”ក្តី ក៏មានសមាជិកខ្មែរ បានលើកអំពីការខ្វះខាតមធ្យោបាយ និងពេលវេលា សំរាប់ទៅធ្វើការពិនិត្យដល់ទីកន្លែង នូវចំណុចព្រំដែន នៃផែនទីថ្មីរបស់វៀតណាមដែរ ។ តែ “អ្នកជំនាញ-ការ”វៀតណាម ឈ្មោះ ផាម(?) ទុន (នៃ ក្រសួងការបរទេស នៃលោក ហ៊ុន សែន) បានលើកទៅវិញថា ភាគីខ្មែរមានការយឺតយ៉ាវច្រើនណាស់ ធ្វើឲ្យភាគីវៀតណាមរង់ចាំយ៉ាងអន្ទះអន្ទែង ហេតុនេះត្រូវពួកខ្មែរ បញ្ចប់សេចក្តីនៃសន្ធិសញ្ញាឲ្យបានរហ័ស ដើម្បីគេចុះហត្ថលេខាជាបន្ទាន់ ។ បន្ថែមលើនេះទៀត ដោយសារ គេធុញទ្រាន់ និងការតវ៉ា ឬការជំទាស់ របស់ពួកអ្នកដឹកនាំបក្សខ្មែរ ផាម(?) ទុន បានដាក់កំហិតឲ្យពួកខ្មែរ នៃ“គណៈកម្មការចំរុះ”នោះ ឲ្យទុកការចរចានិងកិច្ចការទាំងអស់ ជាមួយក្រុងហាណូយ ក្នុងបញ្ហាព្រំដែន “ជាការសម្ងាត់ ចាប់ពីពេលនេះទៅ” ជាដាច់ខាត ។ អាស្រ័យហេតុនេះហើយ ទើបគេបានធ្វើពិធីបោះ បង្គោលសេមាទី១ របស់វៀតណាម “ជាប្រវត្តិសាស្ត្រ” នាឆ្នាំ១៩៨៦ នៅមុខភូមិបាវិតនោះ យ៉ាងស្ងាត់ៗ ដោយតំរូវឲ្យក្រសួងឃោសនាការ និងវប្បធម៌កម្ពុជា គ្រាន់តែទៅ“យកព័ត៌មាន និងថតខ្សែភាពយន្ត... ទុក ជាឯកសារ ដោយឥតផ្សាយទូលាយ”(៤) ។

នៅថ្ងៃនេះ របប“ការសម្ងាត់” នៃបញ្ហាព្រំដែន មានចម្លើយច្បាស់មួយទៀត ដោយនៅថ្ងៃទី ២៦ កញ្ញា ឆ្នាំ២០០៦ នៅក្នុងបទសម្ភាសន៍ឲ្យវិទ្យុសម្លេងសហរដ្ឋអាមេរិក រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាអ្នកនាំ ពាក្យរបស់រាជរដ្ឋាភិបាល លោក ខៀវ កញ្ញារិទ្ធ បានទទួលស្គាល់ថា សន្ធិសញ្ញា ឆ្នាំ១៩៨៥នោះ “មិនមែន ត្រឹមត្រូវសំរាប់ប្រទេសកម្ពុជាទេ ព្រោះវៀតណាមត្រួតត្រាកម្ពុជា នៅពេលនោះ” ។

ដូច្នេះគេត្រូវទទួលស្គាល់ថា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងនានា ស្តីអំពីទឹកដី រវាងវៀតណាមនិង ស.ប.ក. នៅក្នុងរយៈកាលឆ្នាំ១៩៨០នោះ គឺត្រូវបានរៀបចំដោយយួន ដែលក្រុងហាណូយបានបញ្ជូនមក ភ្នំពេញ សំរាប់តំរូវចិត្តយួនហាណូយ ។ ចំណែកឯពួកអ្នកដឹកនាំ“ជាន់ខ្ពស់” នៃបក្សប្រជាជនបដិវត្តកម្ពុជា គេក៏បានដឹងខ្លួនយ៉ាងច្បាស់ថា គេរួមជាមួយលោក ហ៊ុន សែន ក្នុងការកាត់ទឹកដី កោះ ទឹកសមុទ្រ របស់

ប្រទេសខ្លួនទៅឲ្យវៀតណាម ជាថ្នូរនិងកំទេចអំណាច ដែលវៀតណាមប្រគល់ឲ្យ សំរាប់ឲ្យជិះជាន់បង-ប្អូនរួមជាតិខ្លួនឯង នៅក្នុងប្រទេសប៉ុណ្ណោះ ។

បំពោះគណកម្មាធិការព្រំដែនកម្ពុជានៅប្រទេសបារាំង និងនៅលើពិភពលោក គោលជំហ៊ររបស់យើង គ្មានការផ្លាស់ប្តូរឡើយ គឺយើងនៅតែចាត់ទុកថា សន្ធិសញ្ញាដើម និងសន្ធិសញ្ញាបំពេញបន្ថែម រវាងប្រទេស"អាណាព្យាបាល" និងប្រទេស"ក្រោមអាណាព្យាបាល"គេ បានធ្វើឡើងនៅក្រោមការគាបសង្កត់គ្រប់បែបយ៉ាងរបស់គេ ហើយវាឋិតនៅជា សន្ធិសញ្ញាខុសច្បាប់ ដែលមិនអាចទទួលស្គាល់ បានឡើយ ។

## ផលវិបាកនៃ"ការសម្ងាត់"

"ការសម្ងាត់" ដែលជាសញ្ញាត្រានៃអំពើក្បត់នេះ វាបានបញ្ចេញផលនានា ជាធម្មតាមក គឺការភូត-ភរ ការគំរាមកំហែង និងការគាបសង្កត់ នៃអ្នកមាន់អំណាច ក្នុងបញ្ហាព្រំដែន ។ ជាភាពប្រាកដនៅលើក្រដាស់ គេអះអាងថា រាល់សន្ធិសញ្ញា និងកិច្ចព្រមព្រៀង បានធ្វើឡើង"ត្រឹមត្រូវ ស្របតាមគោលការណ៍ច្បាប់ និងទម្លាប់អន្តរជាតិ ក្នុងនាមនៃប្រជារាស្ត្រ និងសំរាប់សុភមង្គលរបស់ប្រជារាស្ត្រ ។ នៅក្នុង"សន្ធិ-សញ្ញាបំពេញបន្ថែម" គេបានសរសេរថា រដ្ឋាភិបាលវៀតណាម និងរដ្ឋាភិបាលកម្ពុជា យកការគោរពគ្នាទៅវិញទៅមក ធ្វើជាគោល ថែមទាំងយក"ការគ្រប់គ្រងពិតប្រាកដ និងការកាន់កាប់ជាក់ស្តែងរបស់ប្រជាជនជាច្រើនជំនាន់" ជាកត្តាសំរាប់ពិនិត្យពិច័យ មុននិងកំរិតខ្សែបន្ទាត់ព្រំដែន ។ តាមការពិត គ្មានឯកសាររបស់រដ្ឋាបាលខ្មែរណាមួយនៅមុនឆ្នាំ១៩៧៩ ត្រូវបានយកមកប្រើដោយលោក ហ៊ុន សែន នៅក្នុងកិច្ចចរចាជាមួយវៀតណាមទេ ហើយគ្មានពេលណាមួយ ដែលប្រជារាស្ត្រខ្មែរ - ទាំងអ្នករស់នៅតាមតំបន់ព្រំដែននោះ នៅរតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀង តាកែវ កំពត ។ល។ ត្រូវបានរដ្ឋាភិបាលហ៊ុន សែន សាកសួរ ឬឲ្យដំណឹង អំពីការផ្លាស់ប្តូរខ្សែព្រំដែន នៅក្នុងតំបន់ ក្នុងឃុំ ក្នុងភូមិ ដែលប្រជារាស្ត្រខ្មែរនោះរស់នៅ ដូចរដ្ឋាភិបាលនានា នៅក្នុងពិភពលោក តែងតែធ្វើជាមួយប្រជារាស្ត្រគេ នោះឡើយ ។ ផ្ទុយទៅវិញ នៅចំពោះការតវ៉ាមិនព្រម របស់ភូមិករ ប្រឆាំងយ៉ាងខ្លាំងតបនិងការកាត់ទឹកដី តបនិងការដែលកង៏ទ័ពយួន មកបណ្តេញចេញពីដីធ្លីរបស់ខ្លួន ដែលខ្លួន ធ្លាប់រស់នៅតាំងតែពីកាលណាកាលណីមក ពួកអាជ្ញាធរភ្នំពេញ ធ្វើជាគ ជាថ្លង់ ឬក៏ចោទដល់ពួកសង្គមស៊ីវិល អ្នកសារ-ព័ត៌មាន ឬអ្នកបដិបក្សនយោបាយ ថាជាអ្នកអុចអាលប្រជារាស្ត្រ ក្នុងបំណងទាញយកចំណេញ "នយោ-បាយ" !។

ហេតុនេះ ដំណើរការបន្ទាប់មកទៀត វាត្រូវទៅតាម "ធម្មតា" របស់វា គឺរដ្ឋសភា នាថ្ងៃទី១១ វិច្ឆិកា ២០០៥ ធ្វើការបោះឆ្នោត ដោយលើកដៃ ដោយ "សំណើរពិសេស" នៃនាយករដ្ឋមន្ត្រី ហ៊ុន សែន ឲ្យអ្នកតំណាងរាស្ត្រ (នៃបក្សប្រជាជនកម្ពុជា រួមគំនិតនិងបក្សហ្វុនស៊ិនប៉ិច) ទទួលយល់ព្រមយក "សន្ធិសញ្ញាបំពេញបន្ថែម" របស់គាត់ "ក្នុងនាមប្រជាជនខ្មែរ" ។ ជាការជាក់ស្តែងមួយទៀត ដើម្បីធ្វើតាម "ការរង់ចាំយ៉ាងអន្ទះអន្ទែង" របស់ក្រុងហាណូយ អ្នកដំណាងរាស្ត្រ និងមហាក្សត្រខ្មែរ មិនត្រូវមានពេលវេលាធ្វើការ

ពិនិត្យពិច័យជាលំអិត លើអត្ថបទនានា ឬក៏បានចុះទៅធ្វើការផ្ទៀងផ្ទាត់នៅលើកន្លែង នូវខ្សែព្រំដែន ដែលយួនបានគូសលើផែនទីឡើយ ។ នៅពេលនោះសោត ប្រទេសកម្ពុជាហាក់ដូចត្រូវស្ថិតក្នុងភាពអាសន្ន ដែលនាយករដ្ឋមន្ត្រីខ្មែរ មានបង្កើតឡើង ដោយគាត់បានគំរាមកំហែងកាប់សម្លាប់ និងធ្វើការ “ប្តូររបបគ្រប់-គ្រងរដ្ឋ”ផង បើសិនជា សន្ធិសញ្ញាយួននេះ មិនបានទទួលសច្ចាប័ន នៅក្រោមហត្ថលេខារបស់គាត់ទេ ។

ដោយបុព្វហេតុទាំងនេះហើយ ទើបប្រជាពលរដ្ឋខ្មែរនៅខេត្តស្វាយរៀង មិនបានត្រូវគេអញ្ជើញ ឲ្យចូលរួមក្នុងពិធី“ជាប្រវត្តិសាស្ត្រ”របស់គេ នៃការបោះបង្គោលសីម៉ា ថ្មី ទី១ នោះទេ ។ ប៉ុន្តែចំពោះ ប្រវត្តិ-សាស្ត្រ នៃប្រទេសកម្ពុជា នៅសម័យថ្មីនេះវិញ គឺបក្សប្រជាជនកម្ពុជា” (ពីមុន ហៅថា“បក្ស ប្រជាជនបដិវត្ត កម្ពុជា”) ដែលមាន លោក ហ៊ុន សែន នាំមុខ ដោយ“មានអំណាចយ៉ាងខ្លាំង” នាពេលបច្ចុប្បន្ន ជាបក្ស ដែលមានមនសិការច្បាស់ ក្នុងការកាត់ដែនសមុទ្រ ទឹកដី របស់កម្ពុជា ទៅឲ្យយួន ! ។

----------

(1) -Journal Cambodge-Soir du 08 septembre 2006, **Frontière khméro-viêtnamienne - Pose de la première borne du nouveau tracé frontalier**, par Chheang Bopha.
(2) -Evan R. Gottesman, **Cambodia After the Khmer rouge: Inside the politics of nation building,** Yale University Press, New Haven, CT, USA, 2003, pp 209-211.

(៣) លិខិត នៃក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា លេខ៣៣១-៨០ កប ចុះថ្ងៃទី១៩ តុលា ១៩៨០ ដោយ ហេង សំរិន ទៅកាន់គណៈកម្មការប្រជាជនបដិវត្តន៍ រដ្ឋធានីភ្នំពេញ ឲ្យ“ធ្វើសហការ ជាមួយជំនាញការវៀតណាម... បញ្ជូនពួក(អាណិកជនវៀត-ណាម) ដែលមក(កម្ពុជា) ដោយខុសច្បាប់នោះ បានវិលទៅប្រទេសគេវិញ” ។

(៤) -លិខិតនៃខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ២៦៣ ល.ស ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៨៦ ដោយអនុរដ្ឋមន្ត្រី ច្បាស់-លាស់ ទៅកាន់រដ្ឋមន្ត្រីក្រសួងឃោសនាការ និងវប្បធម៌ ។

**ក្រុងប៉ារីស ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៦**
ប្រធាន នៃគណកម្មាធិការព្រំដែនកម្ពុជា
ប្រចាំប្រទេសបារាំង និងក្នុងពិភពលោក



**ស៊ាន ប៉េងសែ**